# អកិត្តិជាតក



**ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

*រៀបរៀងដោយ*

*ខ្ញុំព្រះករុណាខ្ញុំបាទ*

**គុល ផេង**

**ព.ស. ២៥៦៤**

# អភិត្តិជាតក

រៀបរៀងដោយ

*បណ្ឌិត* **គុល ផេង**

សីល សមាធិ បញ្ញា

**ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

**ព.ស. ២៥៦៤**

| | |
|---|---|
| ឈ្មោះសៀវភៅ | **អកិត្តិជាតក** |
| រៀបរៀងដោយ | បណ្ឌិត **កុល ផេង**<br>ប្រធានពុទ្ធិកបណ្ឌិតសភា<br>នៃសាកលវិទ្យាល័យ<br>បញ្ញាសាស្ត្រកម្ពុជា |
| ទីតាំងធ្វើ | ពុទ្ធិកបណ្ឌិតសភា |
| ការផ្សាយ | របស់ពុទ្ធិកបណ្ឌិតសភា |
| រក្សាសិទ្ធិ | ពុទ្ធិកបណ្ឌិតសភា |
| កាលបរិច្ឆេទ | ថ្ងៃព្រហស្បតិ៍ ១៥ រោច<br>ខែពិសាខ ឆ្នាំជូត ទោស័ក<br>ព.ស. ២៥៦៤ ច.ល.<br>១៣៨២ ម.ស. ១៩៤២<br>ត្រូវនឹងថ្ងៃទី ២១ ខែ<br>ឧសភា គ.ស. ២០២០ |

# អភិត្តិជាតក

## បុព្វនិទាន

ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធឧបាសកជា**ទានបតី** អ្នកនៅក្នុងក្រុងសាវត្ថីមួយរូប បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា អភិត្ថិ ទិស្វា សម្មន្តំ ដូច្នេះជាដើម ។

## បច្ចុប្បន្ននិទាន

បានឮមកថា ឧបាសកនោះនិមន្តព្រះសាស្តាហើយថ្វាយមហាទានដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន អស់ ៧ ថ្ងៃ ក្នុងថ្ងៃបញ្ចប់នៃការថ្វាយទាន គាត់ប្រគេនបរិក្ខារទាំងពួង ដល់ព្រះអរិយសង្ឃ ។ ពេលនោះ ព្រះសាស្តាកាលធ្វើអនុមោទនាដល់គាត់ក្នុងកណ្តាលបរិសទ្យ បានត្រាស់ថា "ម្នាលឧបាសក ការបរិច្ចាគរបស់អ្នក ធំធេងណាស់ ឱហ្ន៎ អំពើដែល

អ្នកបានធ្វើនេះ ជាអំពើដែលគេធ្វើបានដោយក្រ ពិតមែនហើយ ឈ្មោះថា ទានវង្សនេះ ជាវង្សរបស់ បោរាណកបណ្ឌិតទាំងឡាយពីបុរាណ ឈ្មោះថា ទាន គឺសូម្បីគ្រហស្ថក្តី សូម្បីបព្វជិតក្តី ក៏គួរតែឲ្យ បោរាណកបណ្ឌិតទាំងឡាយបួសហើយសូម្បីកាល នៅក្នុងព្រៃ សូម្បីបរិភោគស្ទឹកតង្កៀបក្តាម ដែលស្ងោរ ដោយត្រឹមតែទឹក មិនប្រៃ មិនមានក្លិន ក៏នៅឲ្យទាន ដល់យាចកដែលមកដល់ហើយ ដរាបដល់សេចក្តី ត្រូវការ ខ្លួនឯងសុខចិត្តញុំាងអត្តភាពឲ្យប្រព្រឹត្ត ទៅដោយបីតិសុខ" ។ ឧបាសកនោះក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ការថ្វាយបរិក្ខារទាំងពួងនេះ ប្រាកដដល់មហាជនហើយ រឿងព្រះអង្គត្រាស់នោះ មិនប្រាកដ សូមព្រះអង្គត្រាស់សម្តែងរឿងនោះ ដល់ ខ្ញុំព្រះអង្គផង" កាលឧបាសកនោះអារាធនាសូមហើយ ព្រះសាស្តាក៏នាំយកអតីតនិទានមកសម្តែងថា

# អតីតនិទាន

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ ក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូល**ព្រាហ្មណមហាសាល** ដែលមានទ្រព្យ ៨០ កោដិ ពពួកញាតិទាំងឡាយដាក់ឈ្មោះឲ្យលោកថា **អកិត្តិ** ។ ក្នុងកាលអកិត្តិកុមារចេះដើរ ប្អូនស្រីរបស់លោកក៏ប្រសូត ។ ញាតិទាំងឡាយដាក់ឈ្មោះឲ្យនាងថា **យសវតី** ។ ព្រះមហាសត្វកាលមានអាយុ ១៦ ឆ្នាំហើយ ក៏ទៅកាន់នគរតក្កសិលា សិក្សារៀនសូត្រសិល្បសាស្ត្រទាំងពួង ហើយត្រឡប់មក ។

គ្រាកាលបន្ទមកទៀត មាតាបិតារបស់លោកក៏បានធ្វើកាលកិរិយាទៅ ។ ព្រះពោធិសត្វកាលធ្វើ**បេតកិច្ច**ដល់លោកទាំងពីរហើយ ពិរចារណាមើលទ្រព្យសម្បត្តិ ស្តាប់ពាក្យថា "ទ្រព្យមានប្រមាណប៉ុណ្ណោះ ឈ្មោះឯណោះ ដែលមាតាបិតារៀបចំទុក

ដាក់មកហើយអំពីអតីត" ដូច្នេះ លោកមានសេចក្តី សង្វេគ គិតថា "ទ្រព្យនេះឯងប្រាកដនៅ ឯអ្នករកទ្រព្យមិនប្រាកដ ជនទាំងអស់នោះលះបង់ទ្រព្យហើយទៅ ចំណែកយើងនឹងកាន់យកទ្រព្យនោះហើយនឹងទៅ" ដូច្នេះទើបហៅប្អូនស្រី មកប្រាប់ថា "នាងចូរគ្រប់គ្រងទ្រព្យនេះចុះ" ។ នាងយសវតីសួរថា អធ្យាស្រ័យរបស់បងដូចម្តេច ? ព្រះមហាសត្វពោលថា យើងប្រាថ្នានឹងបួស ។ នាងយសវតីពោលថា "បពិត្របងប្រុស ខ្ញុំនឹងមិនទទួលទឹកមាត់ដែលបងស្តោះហើយដោយសិរសាឡើយ ខ្ញុំមិនមានសេចក្តីប្រាថ្នាដោយទ្រព្យ សូម្បីខ្ញុំក៏នឹងបួស" ។ អកិត្តិបណ្ឌិតក្រាបទូលព្រះរាជា ហើយឲ្យគេត្រាច់វាយស្គរប្រកាសថា "អ្នកណាត្រូវការទ្រព្យ ចូរទៅកាន់ផ្ទះរបស់អកិត្តិបណ្ឌិតចុះ" ។

ព្រះមហាសត្វញុំាងមហាទានឲ្យប្រព្រឹត្តទៅអស់ ៧ ថ្ងៃហើយ ទ្រព្យសម្បត្តិនៅតែមិនអស់

*ទើបគិតថា "សង្ខារទាំងឡាយនេះតែងអស់ទៅ ការលេងដោយទ្រព្យ នឹងមានប្រយោជន៍អ្វីដល់យើង អ្នកណាត្រូវការ នឹងកាន់យកទ្រព្យនោះចុះ" ដូច្នេះហើយ លោកបើកទ្វារនិវេសន៍ ប្រកាសថា "យើងឲ្យទ្រព្យសម្បត្តិទាំងអស់ អ្នកទាំងឡាយចូរមកនាំយកទៅចុះ" រួចហើយលោកលះបង់ផ្ទះព្រមទាំងមាសប្រាក់ កាលមណ្ឌលនៃញាតិកំពុងបរិទេវៈនោះឯង លោកកាន់យកប្អូនស្រី ចាកចេញអំពីនគរពារាណសី ។ លោកចេញទៅតាមទ្វារណា ទ្វារនោះក៏មានឈ្មោះថា* ***អកិត្តិទ្វារ****, លោកចូងស្ពឹងតាមកំពង់ណា កំពង់នោះក៏មានឈ្មោះថា* ***អកិត្តិតិត្ថៈ*** *។ លោក (ធ្វើដំណើរ) ទៅបានប្រមាណប្រហែលជា ២-៣ យោជន៍ ក៏បានសាងបណ្ណសាលា ក្នុងស្ថានទីជាទីគួររីករាយមួយ ហើយបួសមួយអន្លើដោយប្អូនស្រី ។ ចាប់អំពីកាលដែលព្រះពោធិសត្វបួសហើយ អ្នកស្រុក និគម និងអ្នករាជធានីជាច្រើន នាំគ្នាបួស (តាម) ។*

*ព្រះពោធិសត្វក៏ជាអ្នកមានបរិវារច្រើន, លាភសក្ការៈដ៏ធំបានកើតឡើង ហាក់បីដូចជា កាលកើតឡើងនៃព្រះពុទ្ធដែរ ។*

*លំដាប់នោះ ព្រះមហាសត្វគិតថា "លាភសក្ការៈនេះធំណាស់ សូម្បីបរិវារក៏ច្រើនដែរ តែយើងគួរដើម្បីនៅតែម្នាក់ឯងប៉ុណ្ណោះ" គិតហើយ លោកមិនឲ្យអ្នកណាដឹង សូម្បីតែប្អូនស្រី លោកចេញទៅតែម្នាក់ឯងក្នុងវេលារិកាល ទៅតាមលំដាប់រហូតដល់**រដ្ឋទមិឡ**[១] អាស្រ័យនៅក្នុងឧទ្យាន ដែលនៅជិតកំពង់**កាវីរបដ្ដនៈ** ហើយបានញុំាងឈាន និង*

---

[១] **ទមិឡ** ( ន. ) *[ទៈមិល, ឬតាមទម្លាប់ថា ទ្មិល]  ( បា., សំ. )* (ទ្រាវិឌ) ពួកមនុស្សជាតិមួយនៅក្នុងប្រទេសឥណ្ឌា ទិសនិរតីប៉ែកខាងកើត : *ជាតិទមិឡ ពួកទមិឡ* ។ ខ្មែរយើងប្រើជា គុ. ក៏បាន : *ចិត្តទមិឡ, មនុស្សទមិឡ សំដៅសេចក្ដីថា ចិត្តកាច, មនុស្សកាចអាក្រក់ ប៉ុន្តែតាមការណ៍ពិត ជនជាតិទមិឡ ពុំកាចស្លូតខុសពីជនជាតិដទៃទេ ។*

*អភិញ្ញាឲ្យកើតឡើង ។ លាភសក្ការៈដ៏ច្រើន ក៏បាន កើតឡើងដល់ព្រះពោធិសត្វសូម្បីនៅក្នុងទីនោះ ។ ព្រះមហាសត្វខ្ពើមឆ្អើមលាភសក្ការៈ លោកលះបង់ លាភសក្ការៈនោះ ហើយទៅតាមអាកាស ចុះលើកោះ* ***ការទ្វីប*** *(កោះតង្កៀបក្ដាម) ដែលនៅជិត****នាគទ្វីប*** *។ ក្នុងគ្រានោះ* ***ការទ្វីប*** *មានឈ្មោះថា* ***អហិទ្វីប*** *(កោះពស់) ។ ព្រះមហាសត្វសាងបណ្ណសាលានៅជិតដើម តង្កៀបក្ដាមដ៏ធំមួយ ហើយសម្រេចការនៅលើកោះ នោះ ។ ការដែលលោកនៅក្នុងទីនោះ មិនមាន អ្នកណាដឹងឡើយ ។ គ្រានោះ ប្អូនស្រីរបស់លោក កាលដើរស្វែងរកលោក ក៏ទៅដល់រដ្ឋទមិឡដោយ លំដាប់ តែមិនឃើញព្រះពោធិសត្វ (ក៏ត្រឡប់មក) នៅក្នុងទីដែលនាងធ្លាប់នៅនោះឯង តែមិនអាចញុំាង ឈានឲ្យកើតឡើងឡើយ ។*

*ព្រោះភាពជាអ្នកប្រាថ្នាតិច ព្រះមហាសត្វមិន ទៅកាន់ទីណាមួយឡើយ លោកបរិភោគផ្លែ ក្នុងកាល*

ដែលមានផ្លែរបស់ដើមតង្កៀបក្តាមនោះ ក្នុងកាល ដែលមានស្ទឹក លោកក៏បរិភោគស្ទឹកដែលស្ងោរ ដោយទឹក ។ ដោយតេជះសីលរបស់ព្រះពោធិសត្វ **បណ្ឌុកម្ពលសិលាសនៈ**របស់សក្កទេវរាជ សម្ដែង អាការៈក្ដៅ ។ ស្ដេចសក្កៈគិតថា "តើអ្នកណាហ្ន៎ ប្រាថ្នាឲ្យយើងឃ្លាតចាកអាសនៈ" កាលពិចារណា ក៏ឃើញអកិត្តិបណ្ឌិត ហើយទ្រង់ត្រិះរិះថា "តាបស នោះរក្សាសីលដើម្បីប្រយោជន៍អ្វី លោកប្រាថ្នាភាព ជាសក្កទេវរាជឬ ឬក៏ប្រាថ្នាយ៉ាងដទៃ យើងនឹងសាក ល្បងលោកមើល តាបសនេះសម្រេចការចិញ្ចឹមជីវិត ដោយលំបាក ឆាន់ស្ទឹកតង្កៀបក្តាមដែលស្ងោរដោយ ទឹក បើប្រាថ្នាភាពជាសក្កទេវរាជ លោកនឹងឲ្យស្ទឹក តង្កៀបក្តាមរបស់ខ្លួនដល់យើង បើមិនប្រាថ្នា នឹងមិន ឲ្យឡើយ" គិតដូច្នេះហើយ ព្រះអង្គក៏ទៅកាន់ សំណាក់ព្រះពោធិសត្វ ដោយភេទជាព្រាហ្មណ៍ ។

ព្រះពោធិសត្វដាក់ស្លឹកតង្កៀបក្តាមចុះ គិតថា "(កាល) ស្លឹកតង្កៀបក្តាមត្រជាក់ យើងនឹងបរិភោគ" ដូច្នេះទើបអង្គុយត្រង់ទ្វារបណ្ណសាលា ។ ពេលនោះ សក្កទេវរាជមកឈរបិណ្ឌបាត នៅខាងមុខព្រះពោធិសត្វ ។ ព្រះមហាសត្វឃើញសក្កទេវរាជហើយ មានសេចក្តីសោមនស្ស គិតថា "ជាលាភរបស់យើងទេតើ យើងបានឃើញ**យាចក** ថ្ងៃនេះ យើងនឹងញុំាងមនោរថឲ្យដល់ទីបំផុត យើងនឹងឲ្យទាន" គិតរួច លោកកាន់យកភាជនៈដែលដាក់ស្លឹកតង្កៀបក្តាមឆ្អិន ហើយទៅ (និងប្រាថ្នា)ថា "ឥទំ មេ ទានំ សព្ពញ្ញុតញ្ញាណស្ស បច្ចយោ ហោតុ ទានរបស់យើងនេះសូមចូរជាបច្ច័យនៃសព្វញ្ញុតញ្ញាណ" រួចហើយ លោកធ្វើមិនឲ្យមានចំណែកសេសសល់ដល់ខ្លួន ដាក់ចុះក្នុងភាជនៈរបស់សក្កទេវរាជនោះ ។ សក្កព្រាហ្មណ៍កាន់យកស្លឹកតង្កៀបក្តាមនោះហើយទៅបានបន្តិច ក៏អន្តរធានបាត់ទៅ ។

ចំណែកព្រះមហាសត្វឲ្យដល់ព្រាហ្មណ៍ហើយ មិនចម្អិនម្តងទៀត ញ៉ាំងអត្តភាពឲ្យកន្លងទៅ ដោយបីតិសុខប៉ុណ្ណោះ ថ្ងៃស្អែក លោកចម្អិនហើយ ក៏អង្គុយត្រង់ទ្វារបណ្ណសាលានោះឯង ។

សក្កទេវរាជមកហើយដោយភេទជាព្រាហ្មណ៍ម្តងទៀត ។ ព្រះមហាសត្វឲ្យដល់សក្កទេវរាជ ស្លឹកម្តងទៀត ហើយញ៉ាំងអត្តភាពឲ្យកន្លងទៅដោយបីតិសុខយ៉ាងនោះទៀត ។ ស្លឹកក្នុងថ្ងៃទី ៣ ព្រះមហាសត្វក៏បានឲ្យយ៉ាងនោះ ដោយគិតថា "ឱហ្ន៎ ជាលាភរបស់យើងទេតើ យើងអាស្រ័យស្លឹកតង្កៀបក្តាម ជាអ្នកប្រសព្វបុណ្យដ៏ធំ" លោកមានសេចក្តីសោមនស្ស ស្លឹកជាអ្នកទុព្វល (ខ្សោយកម្លាំង) ព្រោះមិនមានអាហារអស់ ៣ ថ្ងៃ ក៏ជាអ្នកមានសភាពស្មើ ចេញពីបណ្ណសាលា ក្នុងវេលាមជ្ឈន្តិកសម័យ អង្គុយពិចារណាទាន ត្រង់ទ្វារបណ្ណសាលា ។ ចំណែកសក្កទេវរាជ គិតថា "ព្រាហ្មណ៍នេះ ប្រាសចាកអាហារ

*អស់ ៣ ថ្ងៃ សូម្បីទុព្វលយ៉ាងនេះ កាលឲ្យទាន ក៏នៅមានចិត្តត្រេកអរហើយឲ្យ សូម្បីភាវៈប្រែប្រួលនៃចិត្តក៏មិនមាន យើងមិនដឹងថា ʽលោកប្រាថ្នាអ្វី ទើបឲ្យទានʼ យើងត្រូវសួរ ស្តាប់អធ្យាស្រ័យរបស់តាបសនោះ នឹងជ្រាបនូវហេតុនៃទាន" ។ កាលមជ្ឈន្តិកសម័យកន្លងទៅហើយ សក្កទេវរាជជាអ្នករុងរឿងដោយសិរីសោភៈដ៏ធំ ហាក់បីដូចជាព្រះសូរិយាដែលទើបនឹងរះ មកឋិតនៅខាងមុខព្រះមហាសត្វសួរថា "បពិត្រតាបសដ៏ចម្រើន កាលកម្តៅនិងខ្យល់បក់បោកយ៉ាងនេះ លោកម្ចាស់ធ្វើតបោកម្មដើម្បីអ្វីក្នុងព្រៃដែលឡោមព័ទ្ធដោយទឹកប្រៃ មានសភាពបែបនេះ" ។*

តមត្ថំ បកាសេន្តោ សត្ថា បឋមំ

*គាថមាហ ព្រះសាស្តាកាលប្រកាសសេចក្តីនោះ ទើបត្រាស់គាថាទី ១ ថា*

**អកិត្តឹ ទិស្វា សម្មន្តំ, សក្កោ ភូតបតី ព្រវិ;**
**កឹ បត្ថយំ មហាព្រហ្មេ, ឯកោ សម្មសិ ឃម្មនិ។**

*សក្កទេវរាជ ជាម្ចាស់នៃសត្វ លុះឃើញអកិត្តិបណ្ឌិត កំពុងគង់នៅ ទើបសួរថា បពិត្រមហាព្រហ្មលោកប្រាថ្នាចង់បានអ្វី បានជាមកអង្គុយ នៅក្នុងទីក្តៅម្នាក់ឯង ។*

*បណ្តាបទទាំងនោះ បទថា កឹ បត្ថយំ សេចក្តីថា លោកប្រាថ្នាមនុស្សសម្បត្តិឬ ឬក៏ប្រាថ្នាសម្បត្តិដទៃយ៉ាងណាមួយ មានសក្កសម្បត្តិជាដើម ។*

*ព្រះមហាសត្វស្តាប់ពាក្យនោះហើយ ដឹងភាពជាព្រះឥន្ទរបស់ព្រាហ្មណ៍នោះ ក៏ពោលថា "អាត្មាមិនប្រាថ្នាសម្បត្តិទាំងនោះទេ អាត្មាកាលប្រាថ្នាសព្វញ្ញុតញ្ញាណ ទើបធ្វើតបោកម្ម" ដូច្នេះដើម្បីប្រកាសសេចក្តីនោះ ទើបលោកពោលគាថាទី ២ ថា*

**ទុក្ខោ បុនព្ភវោ សក្ក, សរីរស្ស ច ភេទនំ;**
**សម្មោហមរណំ ទុក្ខំ, តស្មា សម្មាមិ វាសវ។**

បពិត្រសក្កៈ ការកើតក្នុងភពថ្មីទៀត នាំមកនូវសេចក្ដីទុក្ខ ការបែកធ្លាយនៃសរីរៈ នាំមកនូវសេចក្ដីទុក្ខ ការស្លាប់ព្រោះតែវង្វេង ក៏នាំមកនូវសេចក្ដីទុក្ខ បពិត្រវាសវៈ ហេតុនោះ បានជាអាត្មា (អង្គុយប្រាថ្នាព្រះនិព្វាន) ។

*បណ្ដាបទទាំងនោះ បទថា តស្មា សេចក្ដីថា ព្រះមហាសត្វសម្ដែងភាពដែលលោកមានអធ្យាស្រ័យក្នុងព្រះនិព្វានយ៉ាងនេះថា ការកើតក្នុងភពថ្មីរឿយៗក្ដី ការបែកធ្លាយនៃខន្ធក្ដី សេចក្ដីស្លាប់ដោយមោហៈក្ដី តែងនាំមកនូវទុក្ខ ព្រោះហេតុណា ព្រោះហេតុនោះ សេចក្ដីទុក្ខទាំងនោះ រមែងមិនមានក្នុងព្រះនិព្វានណា អាត្មាកាលប្រាថ្នាព្រះនិព្វាននោះ ទើបនៅក្នុងទីនេះ ។*

សក្កទេវរាជស្ដាប់ពាក្យនោះហើយ មានចិត្តត្រេកអរ គិតថា "បានឮថា តាបសនេះ ជាអ្នកនឿយណាយក្នុងភពទាំងពួង នៅក្នុងព្រៃដើម្បីប្រាថ្នាព្រះនិព្វាន យើងនឹងឲ្យពរដល់លោក" កាលនិមន្តតាបសដោយពរ ទើបពោលគាថាទី ៣ ថា

**ឯតស្មិំ តេ សុលបិតេ, បតិរូបេ សុភាសិតេ;**
**វរំ កស្សប តេ ទម្មិ, យំ កិញ្ចិ មនសិច្ឆសិ។**

សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្ត ប្រាថ្នាចង់បានពរណា ខ្ញុំប្រគេនពរនោះ ដល់លោក ។

បណ្ដាបទទាំងនោះ បទថា យំ កិញ្ចិ មនសិច្ឆសិ សេចក្ដីថា លោកម្ចាស់មានចិត្ត ប្រាថ្នាពរណា ខ្ញុំឲ្យពរនោះ លោកចូរទទួលពរចុះ ។

ព្រះមហាសត្វកាលទទួលពរ ទើបពោលគាថាទី ៤ ថា

**វរញ្ចេ មេ អទោ សក្ក, សព្វភូតានមិស្សរ;**
**យេន បុត្តេ ច ទារេ ច, ធនធញ្ញំ បិយានិ ច;**
**លទ្ធា នរា ន តប្បន្តិ, សោ លោភោ ន មយី វសេ។**

បពិត្រសក្កៈ ជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា នរជនបានកូន ប្រពន្ធ ទ្រព្យ ស្រូវ និងវត្ថុដទៃ ជាទីស្រឡាញ់ រមែងមិនឆ្អែតស្កប់ស្កល់ដោយលោភៈណា សូមកុំឲ្យលោភៈនោះ នៅក្នុងសន្ដានរបស់អាត្មាបានឡើយ ។

បណ្ដាបទទាំងនោះ បទថា វរញ្ចេ មេ អទោ សេចក្ដីថាប្រសិនបើមហាបពិត្រប្រទានពរដល់អាត្មា ។ បទថា បិយានិ ច សេចក្ដីថា និងភណ្ឌជាទីពេញចិត្តដទៃណាៗ ។ បទថា ន តប្បន្តិ សេចក្ដីថា ជន

ទាំងឡាយតែងប្រាថ្នាសម្បត្តិមានកូនជាដើមរឿយៗ
រមែងមិនឆ្អែតស្កប់ស្កល់ ។ បទថា ឆ មយិ វសេ
សេចក្តីថា សូមលោភៈនោះកុំមាននៅក្នុងអាត្មា
គឺកុំកើតឡើងដល់អាត្មា ។

លំដាប់នោះ ស្តេចសក្កៈត្រេកអររីករាយ
កាលនឹងប្រទានពរសូម្បីឲ្យក្រៃលែងឡើង និង
ព្រះមហាសត្វកាលនឹងទទួលពរ ទើប (លោកទាំងពីរ)
ពោលគាថា (ឆ្លងឆ្លើយ) ទាំងនេះថា

**ឯតស្មឹ តេ សុលបិតេ, បតិរូបេ សុភាសិតេ;**
**វរំ កស្សប តេ ទម្មិ, យំ កិញ្ចិ មនសិច្ឆសិ។**

(សក្កៈ...) សុភាសិតដ៏សមគួរនេះ លោកបាន
ពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្ត ប្រាថ្នា
ពរណា ខ្ញុំប្រគេនពរនោះ ដល់លោក ។

**វរញ្ចេ មេ អទោ សក្ក, សព្ពភូតានមិស្សរ;**

ខេត្តំ វត្ថុំ ហិរញ្ញញ្ច, គវាស្សំ ទាសបោរិសំ;
យេន ជាតេន ជីយន្តិ, សោ ទោសោ ន មយី វសេ។

*(អកិត្តិ...) បពិត្រសក្កៈ ជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា ពួកជនរមែងញុំាងស្រែ ចម្ការ ប្រាក់មាស គោសេះ និងទាសបុរស ឲ្យសាបសូន្យ ដោយទោសៈណា ដែលកើតហើយ សូមកុំឲ្យទោសៈនោះ នៅក្នុងសន្តានអាត្មាបានឡើយ ។*

ឯតស្មិំ តេ សុលបិតេ, បតិរូបេ សុភាសិតេ;
វរំ កស្សប តេ ទម្មិ, យំ កិញ្ចិ មនសិច្ឆសិ។

*(សក្កៈ...) សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំប្រគេនពរនោះ ដល់លោក ។*

វរញ្ចេ មេ អទោ សក្ក, សព្វភូតានមិស្សរ;
ពាលំ ន បស្សេ ន សុណេ, ន ច ពាលេន សំវសេ;

ពាលេនល្លាបសល្លាបំ, ន ករេ ន ច រោចយេ។

*(អកិត្តិ....) បពិត្រសក្កៈ ជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា អាត្មាសូមកុំឲ្យជួបនឹងមនុស្សពាល សូមកុំឲ្យឮដំណឹងមនុស្សពាល សូមកុំឲ្យនៅរួមនឹងមនុស្សពាល សូមកុំឲ្យបានធ្វើ ទាំងកុំឲ្យពេញចិត្តនឹងការចរចាទៅមកនឹងមនុស្សពាល ។*

កិំ នុ តេ អករំ ពាលោ, វទ កស្សប ការណំ;
កេន កស្សប ពាលស្ស, ទស្សនំ នាភិកង្ខសិ។

*(សក្កៈ...) មនុស្សពាលបានធ្វើអ្វីដល់លោក បពិត្រកស្សបៈ សូមលោកប្រាប់ហេតុ បពិត្រកស្សបៈ ហេតុអ្វី បានជាលោកមិនប្រាថ្នាជួបមនុស្សពាល ។*

អនយំ នយតិ ទុម្មេធោ, អធុរាយំ និយុញ្ជតិ;
ទុន្នយោ សេយ្យសោ ហោតិ, សម្មា វុត្តោ បកុប្បតិ;
វិនយំ សោ ន ជានាតិ, សាធុ តស្ស អទស្សនំ។

(អកិត្តិ...) បុគ្គលពាល រមែងណែនាំនូវអំពើមិនគួរណែនាំ រមែងប្រកបក្នុងកិច្ចមិនមែនជាធុរៈ ការណែនាំទៅរកអាក្រក់ ជាការប្រសើរ (របស់បុគ្គលពាលនោះ) បុគ្គលពាល បើទុកជាគេនិយាយត្រូវ ក៏នៅតែខឹង បុគ្គលពាល រមែងមិនដឹងច្បាប់អ្វីទេ ការមិនជួបប្រទះនឹងបុគ្គលពាលនោះ ជាការប្រពៃ ។

ឯតស្មឹ តេ សុលបិតេ, បតិរូបេ សុភាសិតេ;
វរំ កស្សប តេ ទម្មិ, យំ កិញ្ចិ មនសិច្ឆសិ។

(សក្កៈ...) សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំប្រគេនពរនោះ ដល់លោក ។

វរញ្ចេ មេ អទោ សក្ក, សព្ពភូតានមិស្សរ;
ធីរំ បស្សេ សុណេ ធីរំ, ធីរេន សហ សំវសេ;
ធីរេនល្លាបសល្លាបំ, តំ ការេ តញ្ចេ រោចយេ។

(អកិត្តិ....) បពិត្រសក្កៈ ជាធំជាងសត្វទាំងពួង បើព្រះអង្គនឹងប្រទានពរដល់អាត្មា អាត្មាសូមឲ្យជួបប្រទះអ្នកប្រាជ្ញ សូមឲ្យស្តាប់អ្នកប្រាជ្ញ សូមឲ្យនៅរួមជាមួយនឹងអ្នកប្រាជ្ញ សូមឲ្យបានធ្វើ ទាំងសូមឲ្យបានចូលចិត្តនឹងការចរចាទៅមកជាមួយនឹងអ្នកប្រាជ្ញនោះ ។

កឹំ នុ តេ អការំ ធីរោ, វទ កស្សប ការណំ;
កេន កស្សប ធីរស្ស, ទស្សនំ អភិកង្ខសិ។

(សក្កៈ....) អ្នកប្រាជ្ញបានធ្វើប្រយោជន៍អ្វី ដល់លោក បពិត្រកស្សបៈ សូមលោកប្រាប់ហេតុ បពិត្រកស្សបៈ ហេតុអ្វីបានជាលោកចង់ជួបប្រទះអ្នកប្រាជ្ញ ។

នយំ នយតិ មេធាវី, អធុរាយំ ន យុញ្ជតិ;
សុនយោ សេយ្យសោ ហោតិ, សម្មា វុត្តោ ន កុប្បតិ;
វិនយំ សោ បជានាតិ, សាធុ តេន សមាគមោ។

(អកិត្តិ....) អ្នកប្រាជ្ញ រមែងណែនាំនូវហេតុ ដែលគួរដឹកនាំ រមែងមិនប្រកបក្នុងកិច្ច ដែលមិនមែន ជាធុរៈ ការដឹកនាំល្អ ជាការប្រសើរ (របស់អ្នកប្រាជ្ញ នោះ) អ្នកប្រាជ្ញ បើគេនិយាយត្រូវហើយ រមែងមិន ក្រោធ អ្នកប្រាជ្ញនោះ រមែងចេះដឹងច្បាប់ ការសេពគប់ ជាមួយនឹងអ្នកប្រាជ្ញនោះ ជាការប្រពៃ ។

ឯតស្មិំ តេ សុលបិតេ, បតិរូបេ សុភាសិតេ;
វរំ កស្សប តេ ទម្មិ, យំ កិញ្ចិ មនសិច្ឆសិ។

(សក្កៈ....) សុភាសិតដ៏សមគួរនេះ លោកបាន ពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នា ពរណា ខ្ញុំនឹងប្រគេនពរនោះ ដល់លោក ។

វរញ្ចេ មេ អទោ សក្ក, សព្វភូតានមិស្សរ;
តតោ រត្យា វិវសានេ, សូរិយុគ្គមនំ បតិ;
ទិព្វា ភក្ខា បាតុភវេយ្យុំ, សីលវន្តោ ច យាចកា។

**ទទតោ មេ ន ខីយេថ, ទត្វា នានុតបេយ្យហំ;**
**ទទំ ចិត្តំ បសាទេយ្យំ, ឯតំ សក្ក វរំ វរេ។**

*(អកិត្តិ....) បពិត្រសក្កៈ ជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា នាកាលរាត្រីនោះ អស់ហើយ ព្រះអាទិត្រក៏រះឡើង សូមឲ្យទិព្វភោជន កើតប្រាកដ ទាំងពួកយាចកអ្នកមានសីល (ក៏ឲ្យមក) កាលបើអាត្មាឲ្យ សូមទិព្វភោជនកុំឲ្យអស់ លុះឲ្យ ហើយ សូមកុំឲ្យក្តៅក្រហាយស្តាយក្រោយ កាលបើ កំពុងឲ្យ គប្បីឲ្យមានចិត្តជ្រះថ្លា បពិត្រសក្កៈ សូម ព្រះអង្គប្រទានពរនុ៎ះចុះ ។*

**ឯតស្មឹ តេ សុលបិតេ, បតិរូបេ សុភាសិតេ;**
**វរំ កស្សប តេ ទម្មិ, យំ កិញ្ចិ មនសិច្ឆសិ។**

*(សក្កៈ....) សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំនឹងប្រគេនពរនោះ ដល់លោក ។*

វរញ្ចេ មេ អទោ សក្ក, សព្វភូតានមិស្សរ;
ន មំ បុន ឧបេយ្យាសិ, ឯតំ សក្ក វរំ វរេ។

*(អកិត្តិ....) បពិត្រសក្កៈ ជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា ព្រះអង្គកុំចូលមករកអាត្មាទៀតឡើយ បពិត្រសក្កៈ សូមព្រះអង្គប្រទានពរនុ៎ះចុះ ។*

ពហូហិ វតចរិយាហិ, នរា ច អថ នារិយោ;
ទស្សនំ អភិកង្ខន្តិ, កឹ នុ មេ ទស្សនេ ភយំ។

*(សក្កៈ...) ពួកជនប្រុសស្រី តែងចង់ឃើញ (ខ្ញុំ) ដោយការប្រព្រឹត្តវត្តដ៏ច្រើន ចុះភ័យដូចម្ដេចក្នុងការឃើញខ្ញុំ (មានដល់លោក) ។*

**តំ តាទិសំ ទេវវណ្ណំ, សព្ពកាមសមិទ្ធិនំ;**
**ទិស្វា តតោ បមជ្ជេយ្យំ, ឯតំ តេ ទស្សនេ ភយំ។**

*(អកិត្តិ....) អាត្មាឃើញព្រះអង្គ មានភេទជាទេវតាប្រាកដដូច្នោះ មានសេចក្តីប្រាថ្នាទាំងពួងសម្រេចហើយ គប្បីប្រហែសក្នុងតបធម៌ ភ័យក្នុងការឃើញព្រះអង្គនុ៎ះ មានដល់ (អាត្មា) ។*

*សក្កទេវរាជពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ប្រពៃណាស់ ចាប់អំពីពេលនេះទៅ ខ្ញុំនឹងមិនទៅកាន់សំណាក់លោកម្ចាស់ទៀតទេ" ថារួច ទ្រង់ថ្វាយបង្គំព្រះពោធិសត្វ សូមខមាទោស ហើយចៀសចេញទៅ ។*

## ជាតកសារោធ

*ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយទ្រង់ប្រជុំជាតកថា*

- តទា សក្កោ អនុរុទ្ធោ អហោសិ

  *សក្កទេវរាជក្នុងកាលនោះ បានមកជា អនុរុទ្ធ ។*

- អកិត្តិបណ្ឌិតោ បន អហមេវ អហោសិំ ចំណែកអកិត្តិបណ្ឌិត គឺ

  *តថាគតនេះឯង ។*

*អកិត្តិជាតក ចប់ ៕*

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក តេរសកនិបាត អកិត្តិជាតក បិដកលេខ ៥៩ ទំព័រ ២៨៥)*

*ថ្ងៃព្រហស្បតិ៍ ១៥ រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤*

*ច.ល. ១៣៨២ ម.ស. ១៩៤២*

*ត្រូវនឹងថ្ងៃទី ២១ ខែឧសភា គ.ស. ២០២០*



បពិត្រសក្កៈ ជាធំជាងសត្វទាំងពួង បើព្រះអង្គនឹង ប្រទានពរដល់អាត្មា អាត្មាសូមឲ្យជួបប្រទះអ្នកប្រាជ្ញ សូមឲ្យស្តាប់អ្នកប្រាជ្ញ សូមឲ្យនៅរួមជាមួយនឹងអ្នកប្រាជ្ញ សូមឲ្យបានធ្វើ ទាំងសូមឲ្យបានចូលចិត្តនឹងការចរចាទៅមកជាមួយនឹងអ្នកប្រាជ្ញនោះ